# រឿង មហាចោរនៅទល់ដែន

## ភាគទី២៣

ល្ងាចថ្ងៃ ដែលមានការវិវាទ រវាងមានន្ទ និង កាមានេះ ព្រះកម្ពុតជាបិតា ពុំបានទៅណាទេ។ នៅក្នុងដំណាក់ គេឮសូរ តូរ្យតន្ត្រីរងំៗ យូរៗ ចម្រៀងកញ្ញាម្នាក់ លាន់ឮឡើងគ្រលួច រួចគឺសូរមាត់អ្នកសើចហ៊ោកញ្ជៀវ សប្បាយ។ ព្រះកម្ពុត លង់ក្នុងសេចក្តីសប្បាយនេះឯង។ អង្គុយលើកៅអីដាំត្បូង ទ្រង់សំលៀកបំពាក់មួយ ដ៏ល្អឆើតឆាយ ព្រះកម្ពុតទះដៃសើចក្អាកក្អាយ ពីមុខស្រី ដែលរេរាំយ៉ាងស្រស់អស់ពីចិត្ត។ ក្នុងនោះ ទាហានម្នាក់ចូលមក ព្រះកម្ពុតរាដៃ ឲ្យពួករបាំឈប់។ របាំក៏ឈប់ស្ងាត់សូន្យ ។ អ្នករាំក៏លបៗ ចូលទៅកៀនៗ ព្រះកម្ពុត ឱនសួរទៅទាហាន ដែលឈរត្រង់ខ្លួន នៅពីមុខលោកថា៖

- មានការអ្វី ?
- ព្រះបាទម្ចាស់ កាមាត្រូវរបួសជាទំងន់។

ព្រះកម្ពុតឮចំលើយយ៉ាងនោះ បើកភ្នែកធំៗ ញញញ្ញើញសួរតទៅទៀតថា៖

- រឿងអី វានៅឯណា ?
- ព្រះបាទម្ចាស់នៅខាងមុខ មានរឿងជាមួយមានន្ទ។
- យី ! ឯណា ជូនអញទៅ

ព្រះកម្ពុតក៏ដើរចេញពីកៅអីកិត្តិយស ដោយមានទាហានអមទាំងសងខាង ចេញទៅផងៗ។ អ្នកក្មេង អ្នករាំទាំងប៉ុន្មាន ឆ្ងល់នឹងរឿងនេះក្រៃពេក តែពុំមានអ្នកណាមួយ ហ៊ានមាត់កអ្វីឡើយ។ លុះដើរទៅដល់ ឃើញដាក់ជាកាមាមែនហើយ ព្រះកម្ពុតមានទឹកមុខឡើងក្រហម លោកបញ្ជាដូចតទៅ៖

- យកវាទៅថែរក្សាទៅ ! ទៅឆាប់ ៗ!

សេនាជំនិតទាំងអស់ ក៏គ្រាប់កាមាយកទៅ។ ព្រះកម្ពុតដកដង្ហើមធំសម្លឹងទៅក្រៅ ឃើញមនុស្សម្នាក់ក្មេង មុខកាច សក់រួញ ក៏ហៅបុរសនោះ ឲ្យចូលមក។

អត្ថបទដោយ៖ មាស សុភាព

- និលៗ ឯងដឹងរឿងរ៉ាវអ្វីទេ ?
- ព្រះបាទម្ចាស់ ដឹងខ្លះដែរៗ
- អាមានន្ទ និង អាកាមា វាមានរឿងអីនឹងគ្នា ?
- ព្រះបាទម្ចាស់មានរឿងពីស្រីៗ
- ស្រី ? ស្រីអី?
- មានន្ទមានប្រពន្ធមួយ ឈ្មោះនាងទេវី កាមាក៏ស្រលាញ់នាងនេះដែរៗ
- ទេវី ? កូនវិសេសក្លាហាន ដែលទើបស្លាប់ទៅនោះឬ ?
- ព្រះបាទម្ចាស់!
- អាមានន្ទ វាការគ្នាពីកាលណា ?
- បាទទានប្រោស ការរួចប្រហែលមួយឆ្នាំហើយៗ
- យី ! អានេះ ចិត្តធំមែន ! ចុះអាកាមា ម្ដេចក៏វាស្រលាញ់នាងទេវីដែរ ?
- ព្រះបាទម្ចាស់ស្រលាញ់ដែរៗ
- ស្រលាញ់មុន ឬ ក្រោយអាមានន្ទ?
- ព្រះបាទម្ចាស់ស្រលាញ់ក្រោយទេៗ
- រួចវាដណ្ដើមគ្នា ?
- ព្រះបាទម្ចាស់ ប្រហែលដូច្នោះហើយ បានជាកាប់គ្នាថ្ងៃនេះឯងៗ
- ហ៊ឺ ! គិតទៅកូនៗ វាមើលងាយឯងមែនៗ អាអស់នេះ សមតែកាត់ក្បាលវាចោលៗ អាកាមាចុះវានៅក្មេង ចុះអាមនន្ទក្បាល

កញ្ចាស់ ក៏វាព្រើលដែរ រួចវាស្រលាញ់អ្នកណាមិនស្រលាញ់ ទៅស្រលាញ់មីទេវី កូនអាចង្រៃវិសេសក្លាហាន នោះទៀតៗ ហ៎ា ៗ! វាដឹងថាអញស្អប់វិសេសក្លាហាន រួចវាស៊ុមគ្រលុំគ្នាមិនប្រាប់អញៗ តើឥឡូវ អាមានន្ទវាទៅណាហើយ ?

- ព្រះបាទម្ចាស់ ឮថា ជិះសេះទៅខាងមង្គលបុរីៗ

អត្ថបទដោយ៖ មាស សុភាព

- យើ ! អានេះរត់ហើយតើ។ វាដឹងខ្លួនវាហើយ ។ ទៅនិលឯងយកទាហាន ១២នាក់ជិះសេះ ទៅចាប់វាចង នាំមកឲ្យខ្ញុំ យ៉ាងប្រញាប់។
- ខ្ញុំព្រះបាទសុំចុតហ្មាយ ទានប្រោស។
- អើ ៗ !
- ព្រះកម្ពុតសរសេរចុតហ្មាយដូចតទៅ៖

  ចុតហ្មាយឲ្យចាប់ខ្លួន

  យើងព្រះកម្ពុត ចៅហ្វាយខេត្តសិរីសោភ័ណ បង្គប់ឲ្យមេកងនិល ពេជ្រ ចេញមកចាប់មេទ័ពមានន្ទ។

  បើឈ្មោះនេះរឹងទទឹង និលពេជ្រអាចសម្លាប់ចោលបានពេញច្បាប់។

  ព្រះកម្ពុត។

(សូមរង់ចាំតាមដានភាគទី២៤ នៅសប្តាហ៍ក្រោយ)

អរិយធម៌ខ្មែរ
KHMER CIVILIZATION

អត្ថបទដោយ៖ មាស សុភាព